CITY OF LONG BEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃព្រហស្បត្តិ៍ ទី ៣០ ខែកក្កដា ឆ្នាំ ២០២០

ទំនាក់ទំនង៖ Kate Kuykendall
បុគ្គលិកទំនាក់ទំនងសាធារណៈប្រចាំអាកាសយានដ្ឋានទីក្រុងឡុងប៊ិច
ទូរស័ព្ទ៖ 562-570-2679
អ៊ីម៉ែល ៖ kate.kuykendall@longbeach.gov

**សំរាប់ការចេញផ្សាយបន្ទាន់**

# ការកើនឡើងបន្តិចម្តងៗនៃជើងហោះហើរនៅអាកាសយានដ្ឋានឡុងប៊ិច

ទីក្រុងឡុងប៊ិច រដ្ឋកាលីហ្វ័រញ៉ា៖ អាកាសយានដ្ឋានឡុងប៊ិច (LGB) នៅតែបន្តឃើញជើងហោះហើរកើនឡើងបន្តិចម្តងៗយ៉ាងស្ថិតស្ថេរ ដោយកើនពីចំនួនដែលទាបបំផុត ៦ ជើងហោះហើរ ក្នុងរយៈពេលប៉ុន្មានថ្ងៃកាលពីខែមេសា មកជាមធ្យមក្នុងបច្ចុប្បន្ន ១៨ -២០ ជើងហោះហើរប្រចាំថ្ងៃ។ ការផ្លាស់ប្តូរពេលវេលាហោះហើរពីសំណាក់ក្រុមហ៊ុន Delta Air Lines ក៏បង្ហាញពីការកើនឡើងបន្តិចបន្តួចនៃការធ្វើដំណើរកំសាន្តផងដែរ។

ក្រុមហ៊ុន Delta Air Lines បានចេញតារាងពេលហោះហើរថ្មី ដែលបញ្ជាក់ថាខ្លួនចាប់ផ្តើមការហោះហើរឡើងវិញពីអាកាសយានដ្ឋានឡុងប៊ិច នៅថ្ងៃទី០១ ខែសីហា មួយខែមុនការគ្រោងទុក។ ក្រុមហ៊ុន Delta បានប្រកាស បង្រួមជើងហោះហើរជាបណ្តោះអាសន្ននៅក្នុងខែឧសភា ដែលធ្វើឲ្យមានការផ្អាកការហោះហើរពីអាកាសយានដ្ឋានឡុងប៊ិច និងពីអាកាសយានដ្ឋានដ៏ទៃទៀត។ ក្រុមហ៊ុននឹងចាប់ផ្តើមអនុវត្តការហោះហើរដោយផ្ទាល់ពីទីក្រុងឡុងប៊ិចទៅទីក្រុងសលឡេកស៊ីធី (Salt Lake City) ចំនួន ២ ជើងក្នុងមួយថ្ងៃ ហើយរំពឹងថានឹងកើនទៅចំនួន ៥ ជើងក្នុងមួយថ្ងៃ នាថ្ងៃទី ១ ខែតុលា ដោយនឹងកំណត់ទិសដៅហោះហើរជាក្រោយ។

លោកស្រី ស៊ីនធា ហ្គយឌ្រី (Cynthia Guidry) នាយិកានៃអាកាសយានដ្ឋានឡុងប៊ិច បានមានប្រសាសន៍ថា ៖ “ យើងមានភាពរីករាយដែលក្រុមហ៊ុនអាកាសចរណ៍ចាប់ផ្តើមដំណើការហោះហើររបស់ខ្លួនមុនកាលកំណត់ ។ យើងដឹងថាការស្តារឡើងវិញនៃការធ្វើដំណើរកំសាន្តតាមយន្តហោះ មានរយៈពេលឆ្ងាយទៅមុខ ប៉ុន្តែយើងត្រៀមខ្លួនជាស្រេចដើម្បីធ្វើការងារ នៅពេលដែលវាចាប់ផ្តើមកើនឡើងវិញ ” ។

ជាមួយនឹងការចាប់ផ្តើមជើងហោះហើរឡើងវិញរបស់ក្រុមហ៊ុន Delta នៅថ្ងៃទី ០១ ខែសីហា តារាងពេលវេលាហោះហើរនៅអាកាសយានដ្ឋានឡុងប៊ិច នឹងផ្តល់ជូនសេវាកម្មហោះហើរពីសំណាក់ ក្រុមហ៊ុនអាកាសចរណ៍ចំនួន ៤ គឺមាន ៖ American Airlines Delta Air Lines JetBlue Airways និង Southwest Airlines ។ បើតាមការពិនិត្យមើលតារាងហោះហើរក្នុងខែសីហា ក្រុមហ៊ុន JetBlue មានគំរោងប្រតិបត្តិការហោះហើររបស់ខ្លួន ចំនួន ពី ២-៧ ជើងក្នុងមួយថ្ងៃ ហើយ American Airlines នឹងធ្វើការហោះហើរមួយជើងក្នុងមួយថ្ងៃ ទៅទីក្រុងហ្វីនីកស៍ (Phoenix) ។ ក្រុមហ៊ុន Hawaiian Airlines មិនទាន់ចាប់ផ្តើមការហោះហើរនៅឡើយទេ ដោយសាររដ្ឋហាវ៉ៃនៅបន្តអនុវត្តការដាក់ឲ្យនៅដោយឡែក (quarantine) នៅឡើយ។

ឆ្លើយតបទៅនឹងការប្រកាសរបស់ក្រុមហ៊ុន JetBlue ដែលនឹងលុបចោលការហោះហើររបស់ខ្លួននាខែតុលា អាកាសយានដ្ឋាននឹងចាប់ផ្តើមជាផ្លូវការនូវការចែកចាយទីសំចតទាំង ១៧ កន្លែង ទៅតាមបញ្ជីស្នើសុំ ដែលក្នុងនោះរួមមាន ក្រុមហ៊ុន Delta Hawaiian និង Southwest ។ ក្រុមហ៊ុនដទៃទៀតមានឱកាសដាក់ពាក្យចូល ក្នុងបញ្ជីរង់ចាំ រហូតដល់ថ្ងៃទី ២៨ ខែសីហា ដើម្បីចូលរួមក្នុងដំណើការបែងចែកចំណតនេះ។

អាកាសយានដ្ឋានឡុងប៊ិចជាអាកាសយានដ្ឋានមួយដែលមានការកំណត់កំរិតសំលេងរំខានដ៏តឹងរឹងបំផុតនៅក្នុងប្រទេស ហើយអាកាសយានដ្ឋានឡុងប៊ិចផ្តល់ជូនជើងហោះហើរ សរុបចំនួន ៥៣ ។ ការកំណត់ជើងហោះហើរ ត្រូវបានលប់ចោលក្នុងកំឡុងពេលមានជំងឺរាតត្បាតនេះ ។ ដោយមានទីតាំងស្ថិតនៅជាប់ព្រំប្រទល់ នៃខោនទី ឡូសអែនជើឡេស និង អូរេនជ៍ អាកាសយានដ្ឋានឡុងប៊ិចមានទីតាំងនៅជិតកន្លែងកំសាន្តជាច្រើន នៅភាគខាងត្បូងរដ្ឋកាលីហ្វ័រញ៉ា។

## អំពីអាកាសយានដ្ឋានឡុងប៊ិច

អាកាសយានដ្ឋានឡុងប៊ិចបានបង្កើតឡើងក្នុងឆ្នាំ 1923 ហើយជាអាកាសយានដ្ឋាន មុនគេបង្អស់ ក្នុងរដ្ឋកាលីហ្វ័រញ៉ា។ អាកាសយានដ្ឋានឡុងប៊ិចបានទទួលពានរង្វាន់ជាច្រើន ក្នុងនោះបានជាប់ឈ្មោះក្នុងលំដាប់កំពូល១០ នៃការប្រកួតពានរង្វាន់ទេសចរណ៍ប្រភេទ “ អាកាសយានដ្ឋានតូចដ៏ល្អ (Best Small Airport) ” ក្នុងវគ្គ 10Best Readers' Choice របស់សារព័ត៌មាន USA Today ប្រចាំឆ្នាំ២០២០ (2020 USA Today 10Best Readers' Choice) ។

អាកាសយានដ្ឋានឡុងប៊ិច ផ្តល់ជូនជើងហោះហើរដោយផ្ទាល់ទៅទីក្រុងនានាមួយចំនួន ដោយទន្ទឹមគ្នានោះ ធ្វើ ការគាំទ្រសហគមន៍អាកាសចរណ៍ដ៏ផាសុខភាព ដោយមានប្រតិបត្តិការប្រមាណ 300,000 ជារៀងរាល់ឆ្នាំ។ អាកាសយានដ្ឋាននេះក៏ជាប្រភពចំណូល និងប្រភពការងារដ៏សំខាន់ផងដែរ ជាមួយនឹងបណ្តុំអាគារអាកាស យានដ្ឋានឡុងប៊ិច ដែល

CITY OF LONG BEACH **PRESS RELEASE**

ចូលរួមជួយដល់សេដ្ឋកិច្ចប្រមាណ 8.6 ពាន់លានដុល្លា និងគាំទ្រការងារចំនួនប្រមាណ 46,០០០។ អាកាសយានដ្ឋានឡុងប៊ិចជារដ្ឋករស្វយ័តនៃសាលាក្រុងឡុងប៊ិច និងមិនបានទទួលថវិកាពីពន្ធដាក្នុងមូលដ្ឋានទេ។ អាកាសយានដ្ឋានឡុងប៊ិចមានមោទនភាព ក្នុងការថែរក្សាកេរមរតកដ៏មានតម្លៃជាប្រវត្តិសាស្រ្តនេះ និងរក្សាការប្រតិបត្តិប្រកបដោយសុវត្ថិភាព ចេរភាព និងភាពទទួលខុសត្រូវដល់បរិស្ថាន។ សូមតាមយើងខ្ញុំលើទំព័រ Facebook  Twitter និង Instagram តាមរយៈ @LGBAirport ។

## អំពីទីក្រុងឡុងប៊ិច

ទីក្រុងឡុងប៊ិច មានប្រជាជនប្រមាណ 470,000 រូប ហើយជាទីក្រុងដែលបានទទួលចំណាត់ថ្នាក់ និងជាទីក្រុងដែលមាននវានុវត្តភាព។ ទីក្រុងឡុងប៊ិចមានផ្តល់ជូននូវភាពជាទីគាប់ចិត្តលំដាប់អន្តរជាតិ បើប្រៀបទៅនឹងប្រភេទទីក្រុងធំៗ ដោយរក្សានូវភាពជាបុគ្គល និងភាពចម្រុះជាតិសាសន៍ ក្នុងការរស់នៅជុំគ្នា តាមឆ្នេរសមុទ្រ កាលីហ្វ័រញ៉ា ។ ទីក្រុងឡុងប៊ិចជាទីក្រុងដែលមានរចនាសម្ព័ន្ធគ្រប់គ្រងមូលដ្ឋានផ្ទាល់ខ្លួនយ៉ាងពេញលេញ ជាទីសំចតនៃនាវា Queen Mary សួនសត្វសមុទ្រ Aquarium of the Pacific សារមន្ទីរ និងសាលមហោស្រពមួយចំនួន អាជ្ញាធរសិក្សាធិការដែលមានគុណភាពខ្ពស់ អាកាសយានដ្ឋានឡុងប៊ិច និងកំពង់ផែឡុងប៊ិច។ ទីក្រុងឡុងប៊ិចក៏មាន មហាវិទ្យាល័យ និងសកលវិទ្យាល័យ ដែលទទួលបាន ការគោរពកោតសរសើរ កសិដ្ឋានជាប្រវត្តិសាស្រ្តចំនួន ២ មន្ទីរពេទ្យចំនួន ៥ ទីលានវាយកូនគោលចំនួន ៥ សួនឧទ្យានចំនួន ១៧១ ឆ្នេរសមុទ្រ កំពង់ផែកំសាន្ត និងផ្លូវទោចក្រយានដ៏វែងផងដែរ។

សម្រាប់ព័ត៌មានបន្ថែមអំពីទីក្រុងឡុងប៊ិច សូមចូលទៅគេហទំព័រ http://longbeach.gov/ ។ ហើយសម្រាប់ព័ត៌មានថ្មីៗទាន់ហេតុការណ៍ សូមតាមយើងខ្ញុំលើបណ្តាញទំនាក់ទំនងសង្គមតាមរយៈ ៖ Facebook Twitter Instagram និង YouTube។